# គណបក្សប្រជាជនកម្ពុជា

# ឯកសារ

## បំពាក់បំប៉នការងារចាត់តាំង
## កសាងគណបក្ស
## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ចងក្រងផ្សព្វផ្សាយដោយ

គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ឆ្នាំ ២០២៦

**ផ្សព្វផ្សាយផ្ទៃក្នុង**

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្ដាល

ឯកសារបំពាក់បំប៉នជំនាញ
ការងារចាត់តាំងកសាងគណបក្ស

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃចន្ទ ៨កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០២៦

# ឯកសារ
# បំពាក់បំប៉នការងារចាត់តាំងគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ផ្នែកទី ១: គោលការណ៍ការងារចាត់តាំងកសាងគណបក្ស និងតួនាទី ភារកិច្ចរបស់គណៈចាត់តាំង

### I- គោលការណ៍ការងារចាត់តាំងកសាងគណបក្ស

១- មាត្រាទី ៤ ជំពូក II នៃលក្ខន្តិកៈគណបក្ស អំពីគោលការណ៍កសាងគណបក្ស ចំណុច ៤ ចែងថា : "គណបក្សដឹកនាំខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង"

-ដឹកនាំខាងនយោបាយ គឺគណបក្សដាក់ចេញនូវកម្មវិធីនយោបាយ គោលការណ៍ និងគោលនយោបាយនានា សម្រាប់ការអភិវឌ្ឍន៍ប្រទេស ។

-ដឹកនាំខាងសតិអារម្មណ៍ គឺគណបក្សធ្វើការឃោសនា អប់រំ ផ្សព្វផ្សាយ ដើម្បីប្រមូលកម្លាំងសមាជិកគណបក្ស និងមហាជន ប្រជាជនចូលរួមគាំទ្រ និងអនុវត្តកម្មវិធីនយោបាយ គោលការណ៍ និងគោលនយោបាយនានារបស់គណបក្សឱ្យសម្រេចបានជោគជ័យ ។

-ដឹកនាំខាងចាត់តាំង គឺគណបក្សរៀបចំអង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ គ្រប់គ្រងកសាងពង្រឹងពង្រីកសមាជិកគណបក្ស រៀបចំមន្ត្រីដែលមានសមត្ថភាព ប្រកបដោយគុណធម៌ ចូលរួមបំពេញភារកិច្ចក្នុងអង្គការដឹកនាំរបស់គណបក្សគ្រប់ថ្នាក់ និងពិនិត្យវាយតម្លៃ ឧទ្ទេសនាមមន្ត្រីគណបក្សចូលកាន់តំណែងនានាក្នុងស្ថាប័នរដ្ឋ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ។

២- មាត្រាទី ១០ ជំពូក IV នៃលក្ខន្តិកៈគណបក្ស ចែងអំពីខ្លឹមសារជាមូលដ្ឋាននៃគោលការណ៍ចាត់តាំងរបស់គណបក្សគឺ :

មួយ : អង្គការដឹកនាំរបស់គណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ គឺត្រូវបានមហាសន្និបាតបោះឆ្នោតជ្រើសតាំងឡើង ហើយថ្នាក់លើមួយថ្នាក់យល់ព្រមទទួលស្គាល់ ។ ក្នុងករណីដែលពុំអាចបើកមហាសន្និបាតបានទើបថ្នាក់លើចង្អុលតែងតាំងគណៈកម្មាធិការនៃគណបក្សបណ្ដោះអាសន្ន ។

ពីរ : សមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ ។

បី : នៅពេលពិភាក្សារាល់ការងារ ត្រូវគោរពមតិប្រជាធិបតេយ្យពិតប្រាកដ ក្រោយពេលអនុម័ត ភាគតិចត្រូវគោរពភាគច្រើន ។

បួន : សមាជិកម្នាក់ៗត្រូវគោរពអង្គការចាត់តាំង ថ្នាក់ក្រោមត្រូវគោរពថ្នាក់លើ ។ គណបក្សទាំងមូលត្រូវគោរពមហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស និងគណៈកម្មាធិការកណ្ដាលនៃគណបក្ស ។

ប្រាំ : អង្គការចាត់តាំងរបស់គណបក្សគ្រប់ថ្នាក់ ត្រូវខិតខំចាត់តាំងអនុវត្តដោយច្នៃប្រឌិត នូវកម្មវិធីនយោបាយរបស់គណបក្សស្របតាមសភាពការណ៍ជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ។ ពេលមានការងារសំខាន់ៗ ត្រូវសុំយោបល់ពីថ្នាក់លើ ។

៣- មាត្រាទី ១១ ជំពូក IV នៃលក្ខន្តិកៈគណបក្សចែងថា :

អង្គការចាត់តាំងរបស់គណបក្ស ត្រូវបានចាត់តាំងឡើងនៅតាមស្ថាប័ននានា ។ ខ្សែរយៈចាត់តាំងរបស់គណបក្សរួមមាន ៤ ថ្នាក់គឺ :

- ថ្នាក់កណ្តាល
- ថ្នាក់រាជធានី ខេត្ត ក្រសួង ស្ថាប័ន
- ថ្នាក់ ក្រុង ស្រុក ខណ្ឌ
- ថ្នាក់មូលដ្ឋាន

៤- ការកសាងគណបក្សខាងចាត់តាំង គឺធ្វើឱ្យគណបក្សកាន់តែរឹងមាំ និងមានកម្លាំងប្រយុទ្ធខ្លាំង ដើម្បីបំពេញបេសកកម្មបម្រើប្រទេសជាតិ និងប្រជាជនដោយជោគជ័យ ។ ត្រូវកសាងពង្រឹងអង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក ឱ្យមានភាពរឹងមាំ ជឿជាក់ពិតប្រាកដ មានឆន្ទៈមុះមុតក្នុងការបំពេញភារកិច្ច គោរពអង្គការវិន័យរបស់គណបក្ស និងច្បាប់រដ្ឋ មានសាមគ្គីភាពឯកភាពផ្ទៃក្នុងរឹងមាំ និងផ្សារភ្ជាប់ជិតស្និទ្ធជាមួយសមាជិកគណបក្ស និងមហាជន ប្រជាជន ។ កសាងជួរមន្ត្រីគណបក្សដែលមានគោលជំហររឹងមាំ មានគុណធម៌ សីលធម៌ស្អាតស្អំ មានសុខភាព និងសមត្ថភាពអាចដឹកនាំចាត់តាំងអនុវត្តដោយជោគជ័យនូវទិសដៅ ភារកិច្ច គោលការណ៍ និងសេចក្តីសម្រេចនានារបស់គណបក្ស ។ កសាងពង្រឹងពង្រីកសមាជិក និងកម្លាំងគាំទ្រគណបក្សច្រើនកុះករ ចូលរួមគាំទ្រ និងអនុវត្តឱ្យបានសម្រេចជោគជ័យនូវកម្មវិធីនយោបាយរបស់គណបក្ស ។

អង្គការចាត់តាំង និងមន្ត្រីគណបក្សនៅគ្រប់ថ្នាក់ត្រូវអនុវត្តឱ្យបានត្រឹមត្រូវនូវរាល់គោលការណ៍ការងារចាត់តាំងកសាងគណបក្ស ដើម្បីជានាពង្រឹងតួនាទីដឹកនាំរបស់គណបក្ស ពង្រឹងសាមគ្គីភាពឯកភាពផ្ទៃក្នុង និងពង្រឹងជំនឿគាំទ្រចំពោះគណបក្ស ។

## II- តួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំងរបស់គណៈចាត់តាំង

### ក- គណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត

ក១- តួនាទី

គណៈចាត់តាំងនៃគណបក្សរាជធានី ខេត្ត គឺជាអង្គភាពជំនួយការផ្ទាល់របស់គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្នុងការដឹកនាំ ណែនាំ ត្រួតពិនិត្យ និងជំរុញការអនុវត្តគោលការណ៍ការងារចាត់តាំងកសាងគណបក្សនៅក្នុងរាជធានី ខេត្ត សំដៅកសាងពង្រឹងអង្គការចាត់តាំងគណបក្ស កសាងពង្រឹងជួរមន្ត្រីគណបក្ស កសាងពង្រឹងមូលដ្ឋាន ពង្រឹងពង្រីកសមាជិក និងកម្លាំងគាំទ្រគណបក្ស ចូលរួមអនុវត្តឱ្យបានជោគជ័យនូវកម្មវិធីនយោបាយ និងគោលការណ៍នានារបស់គណបក្ស លើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំរបស់អង្គការចាត់តាំងគណបក្ស ពង្រឹងសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងជំនឿគាំទ្រចំពោះការដឹកនាំរបស់គណបក្ស ។

ក២- ភារកិច្ច

១- សិក្សាស្រាវជ្រាវ ស្វែងយល់អំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស គោលការណ៍ គោលនយោបាយ និងទិសដៅ វិធានការការងារចាត់តាំងកសាងគណបក្ស ដើម្បីលើកយោបល់ជូនគណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការ

គណបក្សរាជធានី ខេត្ត សម្រេចដាក់ចេញនូវគោលការណ៍ណែនាំអនុវត្ត ស្របតាមសភាពការណ៍ជាក់ស្តែងនៃមូលដ្ឋាន ដែលរួមមាន :

- អំពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការ របស់អង្គការចាត់តាំងគណបក្ស និងអង្គភាពជំនួយការរបស់គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គការចាត់តាំងមូលដ្ឋានចំណុះ

- អំពីផែនការ ទិសដៅ វិធានការរៀបចំ និងពង្រឹងអង្គការចាត់តាំងគណបក្សក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គការចាត់តាំងមូលដ្ឋានចំណុះ

- អំពីការងារពង្រឹងលើកកម្ពស់គុណភាពសមត្ថភាពជួរមន្ត្រីគណបក្សនៅតាមមន្ទីរអង្គភាពជុំវិញរាជធានី ខេត្ត គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គណៈកម្មាធិការគណបក្សមូលដ្ឋាន និងមន្ត្រីដឹកនាំសាខាគណបក្ស

- អំពីនីតិវិធីជាក់ស្តែង និងលក្ខណសម្បត្តិមន្ត្រីគណបក្ស ដែលត្រូវជ្រើសរើសជាបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតថ្នាក់ក្រោមជាតិ តាមគោលការណ៍ណែនាំរបស់ថ្នាក់លើ

- អំពីនីតិវិធីជាក់ស្តែងក្នុងការពិនិត្យវាយតម្លៃមន្ត្រីគណបក្សដើម្បីស្វាបស្ទង់ជាបេក្ខភាពសម្រាប់ស្នើតែងតាំងតំណែងក្នុងរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរចនាសម្ព័ន្ធមន្ទីរអង្គភាពជំនាញនានានៅថ្នាក់ក្រោមជាតិ និងការរៀបចំមន្ត្រីគណបក្សគ្រប់ថ្នាក់ចំណុះតាមគោលការណ៍ណែនាំរបស់ថ្នាក់លើ

- អំពីលក្ខណសម្បត្តិ និងវិធីជ្រើសរើសមន្ត្រីគណបក្ស និងបុគ្គលិក កម្មករ ចូលបម្រើការងារនៅស្នាក់ការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

- អំពីផែនការ ទិសដៅ វិធានការគ្រប់គ្រង ពង្រឹងសមាជិកគណបក្ស និងបញ្ចូលសមាជិកថ្មី

- អំពីផែនការ ទិសដៅការងារកសាងពង្រឹងមូលដ្ឋានរបស់គណបក្សគ្រប់ថ្នាក់ចំណុះ ។

២- ពិនិត្យសំណើរបស់អង្គការចាត់តាំងគណបក្សចំណុះ ដើម្បីរាយការណ៍ជូនគណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ពិនិត្យសម្រេច អំពីការរៀបចំអង្គការចាត់តាំងគណបក្ស មន្ត្រីគណបក្ស និងបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេស ស្របតាមគោលការណ៍កំណត់របស់គណបក្ស ។

៣- អនុវត្តភារកិច្ចជំនាញការងារចាត់តាំងកសាងគណបក្ស :

- ផ្សព្វផ្សាយ ណែនាំ បំពាក់បំប៉នការងារជំនាញដល់មន្ត្រីគណបក្សគ្រប់ថ្នាក់ចំណុះ និងតាមដានត្រួតពិនិត្យការអនុវត្តគោលការណ៍ការងារចាត់តាំងកសាងគណបក្ស

- គ្រប់គ្រងស្ថិតិអង្គការចាត់តាំងគណបក្ស មន្ត្រី និងសមាជិកគណបក្សចំណុះ

- គ្រប់គ្រងបញ្ជីរាយនាម ជីវប្រវត្តិ និងសំណុំលិខិតផ្ទាល់ខ្លួនរបស់មន្ត្រីគណបក្សដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់គណបក្សរាជធានី ខេត្ត និងមន្ត្រី បុគ្គលិក បម្រើការងារនៅស្នាក់ការគណបក្ស

- គ្រប់គ្រងបញ្ជីរាយនាម និងជីវប្រវត្តិសមាជិកចូលគណបក្សក្នុងករណីពិសេស

- រៀបចំចងក្រងបញ្ជីរាយនាមមន្ត្រីគណបក្ស ដែលបំពេញភារកិច្ចនៅតាមមន្ទីរ អង្គភាពជុំវិញរាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

- រៀបចំចងក្រងឯកសារការងារចាត់តាំងកសាងគណបក្ស និងការគ្រប់គ្រងមន្ត្រីគណបក្ស សមាជិកគណបក្ស តាមប្រព័ន្ធព័ត៌មានវិទ្យា ។

៤- សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យនៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្នុងការត្រួតពិនិត្យណែនាំពង្រឹងអង្គការចាត់តាំងគណបក្សក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមូលដ្ឋាន និងអប់រំណែនាំដល់មន្ត្រីគណបក្សដែលបានប្រព្រឹត្តកំហុសឆ្គង មិនស្របតាមគោលការណ៍របស់គណបក្ស ។

៥- សហការជាមួយគណៈឃោសនាអប់រំនៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងផ្នែកពាក់ព័ន្ធ ក្នុងការជ្រើសរើសមន្ត្រីគណបក្សចូលរួមវគ្គអប់រំនយោបាយរបស់គណបក្សថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត និងវគ្គជំនាញផ្សេងៗទៀតរបស់គណបក្ស ។

៦- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងទៀត ដែលគណៈអចិន្ត្រៃយ៍ និងគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ប្រគល់ជូន ។

**ក៣- រចនាសម្ព័ន្ធចាត់តាំង**

➢ គណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ដឹកនាំដោយប្រធាន ១រូប ដែលជាមន្ត្រីនៅក្នុងជួរគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងមានអនុប្រធាន ១ ទៅ ២រូប មន្ត្រីជំនួយការមួយចំនួន ។

អនុប្រធានទទួលបន្ទុកជួយប្រធានលើការងារមួយចំនួនដែលប្រធានប្រគល់ឱ្យ និងជំនួសប្រធាននៅពេលប្រធានអវត្តមាន តាមការប្រគល់ភារកិច្ចរបស់ប្រធាន ។

➢ គណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត មាន ៣ ការិយាល័យចំណុះដូចខាងក្រោម ៖

១- ការិយាល័យរដ្ឋបាល និងគ្រប់គ្រងទិន្នន័យការងារចាត់តាំង មានភារកិច្ច:

- ការងារលិខិតស្នាមចេញ-ចូល
- ការងារបូកសរុបរបាយការណ៍ ស្ថិតិ
- ការងារគ្រប់គ្រង និងរក្សាទុកឯកសារ
- ការងារគណនេយ្យ
- ការងារគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស និងមន្ត្រីគណបក្ស តាមប្រព័ន្ធព័ត៌មានវិទ្យា
- ការងារបោះពុម្ពប័ណ្ណ និងឯកសារផ្សេងៗ តាមទិន្នន័យចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល
- ការចងក្រង រក្សាទុកទិន្នន័យបម្រើការងារចាត់តាំង កសាងគណបក្ស
- ការងារបំពាក់បំប៉នជំនាញអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យការងារចាត់តាំង ។

២- ការិយាល័យការងារមន្ត្រីគណបក្ស មានភារកិច្ច:

- ស្រាវជ្រាវ លើកយោបល់ដើម្បីណែនាំដាក់ស្តែងអំពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់អង្គការចាត់តាំងគណបក្សពីថ្នាក់រាជធានី ខេត្ត ដល់ថ្នាក់ឃុំ សង្កាត់ ភូមិ
- រៀបចំបែបបទសម្រាប់ការពិនិត្យលើកសំណើសុំបង្កើត ឬរំសាយអង្គការចាត់តាំងគណបក្ស និងការរៀបចំមន្ត្រីគណបក្ស ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់កណ្តាល
- រៀបចំបែបបទសម្រាប់ការពិនិត្យសម្រេចអំពីការបង្កើត ឬរំសាយអង្គការចាត់តាំងគណបក្ស និងការរៀបចំមន្ត្រីគណបក្ស ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់រាជធានី ខេត្ត
- រៀបចំបែបបទសម្រាប់ការពិនិត្យសម្រេចអំពីសមាសភាពក្រុមការងារគណបក្សចុះមូលដ្ឋាន និងក្រុមការងារផ្សេងៗទៀតរបស់គណបក្ស

- រៀបចំបែបបទសម្រាប់ការពិនិត្យសម្រេចអំពីការជ្រើសរើសមន្ត្រី បុគ្គលិក ចូលបម្រើការងារក្នុងអង្គភាពជំនួយការរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងស្នាក់ការគណបក្ស
- រៀបចំគ្រប់គ្រងបញ្ជីរាយនាម ជីវប្រវត្តិ និងសំណុំលិខិតផ្ទាល់ខ្លួនរបស់មន្ត្រីគណបក្សដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់រាជធានី ខេត្ត និងមន្ត្រីបុគ្គលិកស្នាក់ការគណបក្ស
- សហការរៀបចំជ្រើសរើសមន្ត្រីគណបក្សចូលរួមវគ្គអប់រំនយោបាយរបស់គណបក្សថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត និងវគ្គជំនាញផ្សេងៗទៀតរបស់គណបក្ស ។

៣- ការិយាល័យកសាងគណបក្ស មានភារកិច្ច:

- ស្រាវជ្រាវ លើកយោបល់អំពីការណែនាំអនុវត្តលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស ការងាររៀបចំ និងកសាងពង្រឹងសាខាគណបក្ស អនុសាខា ក្រុមបក្ស និងគ្រួសារបក្ស
- រៀបចំបែបបទសម្រាប់ការពិនិត្យសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេស និងពិធីប្រកាសបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេសដោយថ្នាក់រាជធានី ខេត្ត
- រៀបចំបែបបទសម្រាប់ការពិនិត្យសម្រេចចាត់តាំងក្រុមការងារចុះជួយកសាងសមាជិកគណបក្សនៅតាមមូលដ្ឋាន
- រៀបចំបែបបទអំពីការបញ្ចូលសមាជិកគណបក្ស ការគ្រប់គ្រងសមាជិកគណបក្ស និងការផ្ទេរជីវភាពសមាជិកគណបក្ស
- គ្រប់គ្រងបញ្ជីរាយនាម ជីវប្រវត្តិ និងសំណុំលិខិតផ្ទាល់ខ្លួនរបស់សមាជិកចូលគណបក្សក្នុងករណីពិសេស និងក្រុមការងារកសាងសមាជិកគណបក្សនៅតាមមូលដ្ឋាន ដែលសម្រេចដោយថ្នាក់រាជធានី ខេត្ត
- រៀបចំគ្រប់គ្រងស្ថិតិអង្គការចាត់តាំងគណបក្ស និងសមាជិកគណបក្ស ។

**ខ- គណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ**

គណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ គឺជាអង្គភាពជំនួយការផ្ទាល់របស់គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ លើការងារចាត់តាំងកសាងគណបក្ស ។

គណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ មានភារកិច្ចប្រហាក់ប្រហែលគណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ដែលត្រូវអនុវត្តភារកិច្ចក្នុងក្របខណ្ឌក្រុង ស្រុក ខណ្ឌ ។

គណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ដឹកនាំដោយប្រធាន ១រូប ដែលជាមន្ត្រីនៅក្នុងជួរគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ និងមានអនុប្រធាន ១រូប និងជំនួយការ ២រូប ។

គណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ មាន ២ផ្នែកចំណុះ គឺផ្នែករដ្ឋបាល និងគ្រប់គ្រងទិន្នន័យការងារចាត់តាំង និងផ្នែកការងារមន្ត្រីគណបក្ស និងកសាងគណបក្ស ។ ប្រធាន និងអនុប្រធានគណៈចាត់តាំងត្រូវបែងចែកភារកិច្ចដឹកនាំផ្ទាល់ផ្នែកនីមួយៗ ។

**គ- ការរៀបចំរចនាសម្ព័ន្ធអង្គការចាត់តាំង និងបែងចែកភារកិច្ចជាក់ស្តែង**

គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវផ្អែកលើគោលការណ៍អំពីភារកិច្ច និងអង្គការចាត់តាំងរបស់គណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដើម្បីសម្រេចរៀបចំការិយាល័យផ្នែកនីមួយៗ និងបែងចែកភារកិច្ចច្បាស់លាស់ជូនមន្ត្រីក្រោមឱវាទអនុវត្តឱ្យបានល្អ ស្របតាមសភាពការណ៍ជាក់ស្តែង ។

## ផ្នែកទី ២ : គោលការណ៍ការងាររៀបចំរចនាសម្ព័ន្ធ អង្គការចាត់តាំង និងមន្ត្រី គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គការចាត់តាំងមូលដ្ឋានចំណុះ

### I- គណៈកម្មាធិការគណបក្សរាជធានី ខេត្ត

១. រចនាសម្ព័ន្ធចាត់តាំង

- រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវមានមន្ត្រីវ័យចាស់ វ័យក្មេង នារីភេទ ជនជាតិភាគតិច (នៅមូលដ្ឋានដែលមានជនជាតិភាគតិចច្រើន) ហើយជាមន្ត្រីគណបក្សដែលមានលក្ខណសម្បត្តិល្អប្រពៃ មានទស្សនៈ គោលជំហរនយោបាយរឹងមាំ មានគុណធម៌ សីលធម៌ល្អ មានទំនាក់ទំនងល្អជាមួយមហាជន ប្រជាជន មានសមត្ថភាពរួមចំណែកក្នុងការដឹកនាំរួមរបស់គណៈកម្មាធិការគណបក្ស និងមានលទ្ធភាពរ៉ាប់រងការងារគណបក្សដែលបានប្រគល់ជូន ។

- សមាសភាពគណៈកម្មាធិការគណបក្សរាជធានី ខេត្ត រួមមានមន្ត្រីគណបក្សជាអភិបាល អភិបាលរង ប្រធាន និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត (តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាដែលចាំបាច់ មន្ត្រីដែលមានបទពិសោធន៍ក្នុងការដឹកនាំ និងមានឥទ្ធិពលល្អ) ប្រធានគណៈ ប្រធានមន្ទីរគណបក្ស មន្ត្រីដឹកនាំនៅតាមមន្ទីរ អង្គភាពជុំវិញរាជធានី ខេត្ត មន្ត្រីដឹកនាំក្នុងកងកម្លាំងប្រដាប់អាវុធ ប្រធានគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ អភិបាល និងប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។ ប្រធានគណៈ ឬប្រធានមន្ទីរគណបក្សត្រូវតែជាសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស អនុប្រធានគណៈ ឬអនុប្រធានមន្ទីរគណបក្ស ១រូបទៀត អាចជាសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។

គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស រួមមានមន្ត្រីគណបក្សជាប្រធានក្រុមប្រឹក្សា អភិបាល អភិបាលរង រាជធានី ខេត្ត (តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាដែលចាំបាច់ មន្ត្រីដែលមានបទពិសោធន៍ក្នុងការដឹកនាំ និងមានឥទ្ធិពលល្អ) ប្រធានគណៈ ប្រធានមន្ទីរគណបក្ស មន្ត្រីដឹកនាំក្នុងកងកម្លាំងប្រដាប់អាវុធ និងមន្ទីរអង្គភាពសំខាន់ៗជុំវិញរាជធានី ខេត្ត ។ ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការគណបក្សក្រុង ដែលជាទីតាំងរដ្ឋបាលខេត្តអាចជាសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត ។

គណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត រួមមានអនុប្រធានប្រចាំការគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ជាប្រធាន និងសមាជិកដែលជាប្រធានគណៈ ប្រធានមន្ទីរគណបក្សនិងមន្ត្រីដែលទទួលបន្ទុកការងារគណបក្ស ។

+ ជាគោលការណ៍រួម អភិបាលរាជធានី ខេត្ត ត្រូវបានពិនិត្យរៀបចំជាប្រធានគណៈកម្មាធិការគណបក្ស ។ ករណីជាក់ស្តែងមួយចំនួន ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត អាចជាប្រធានគណៈកម្មាធិការគណបក្សបាន ។ រាជធានី ខេត្តដែលមានសមាជិកគណៈកម្មាធិការកណ្តាលចំនួន៣រូបចុះ ត្រូវរៀបចំបែងចែកភារកិច្ចជូនសមាជិកគណៈកម្មាធិការកណ្តាលទាំងអស់ក្នុងជួរគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ។

+ សមាជិកគណៈកម្មាធិការគណបក្សដែលបានទទួលអាណត្តិជាសមាជិកព្រឹទ្ធសភា ឬតំណាងរាស្ត្រ ត្រូវសម្រួលភារកិច្ចពីគណៈកម្មាធិការគណបក្ស ហើយត្រូវបានគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលឧទ្ទេសនាមឱ្យចូលរួមជីវភាពគណបក្សជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត នៃមណ្ឌលបោះឆ្នោតរបស់ខ្លួនរហូតដល់ចប់អាណត្តិ ។

+ សមាជិកគណៈកម្មាធិការកណ្តាលដែលត្រូវបានឈប់សម្រាកពីការងារ ត្រូវបានគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលឧទ្ទេសនាមជូនគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ដើម្បីរៀបចំឱ្យចូលរួមជីវភាពគណបក្សជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ឬគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ដែលសាមីខ្លួនរស់នៅ ។

២. បរិមាណ

បរិមាណសមាជិកគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវបានកំណត់ :

- មានចំនួន៥១ រូបចុះ ចំពោះរាជធានី ខេត្តចំនួន ១៤ : ភ្នំពេញ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង កណ្តាល តាកែវ សៀមរាប កំពង់ស្ពឺ ស្វាយរៀង បាត់ដំបង កំពត កំពង់ធំ បន្ទាយមានជ័យ កំពង់ឆ្នាំង
- មាន៤៩ រូបចុះ ចំពោះខេត្តចំនួន៦ : ពោធិ៍សាត់ ក្រចេះ ព្រះវិហារ រតនគិរី ស្ទឹងត្រែង កោះកុង
- មាន៤៣ រូបចុះ ចំពោះខេត្តចំនួន៥ : មណ្ឌលគិរី ឧត្តរមានជ័យ ព្រះសីហនុ កែប ប៉ៃលិន ។

+ អាចពង្រីកបន្ថែមបរិមាណសមាជិកគណៈកម្មាធិការគណបក្ស នៅក្នុងជួរសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដែលមានគ្រប់លក្ខណសម្បត្តិ ។

+ គណៈអចិន្ត្រៃយ៍មានចំនួនមិនលើស ១ភាគ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្សទាំងមូល ។

+ គណៈប្រចាំការមានចំនួន៧ រូបចុះ និងតិចជាងពាក់កណ្តាលនៃចំនួនសមាជិកគណៈអចិន្ត្រៃយ៍ ។

+ អនុប្រធានគណៈកម្មាធិការគណបក្ស មានចំនួន ២រូប ។ រាជធានី ខេត្តចំនួន ១៤ ខាងដើម អាចរៀបចំឱ្យមានអនុប្រធាន ៣រូប ។

**បញ្ជាក់** : ចំពោះគណៈកម្មាធិការគណបក្សដែលមានគ្រប់បរិមាណកំណត់រួចហើយ ប្រសិនបើមានការតែងតាំងមន្ត្រីជាថ្នាក់ដឹកនាំថ្មី អាចលើកសំណើតែងតាំងបន្ថែមសមាសភាពនៃគណៈកម្មាធិការគណបក្សស្របតាមគោលការណ៍កំណត់អំពីរចនាសម្ព័ន្ធ ។

៣. អង្គភាពជំនួយការគណបក្ស

អង្គភាពជំនួយការគណៈកម្មាធិការគណបក្សរាជធានី ខេត្ត រួមមាន :

- មន្ទីរគណបក្ស (មានប្រធាន អនុប្រធាន និងជំនួយការមួយចំនួន)
- គណៈចាត់តាំង (មានប្រធាន អនុប្រធាន ១ឬ២រូប និងជំនួយការមួយចំនួន)
- គណៈឃោសនាអប់រំ (មានប្រធាន អនុប្រធាន ២រូប និងជំនួយការមួយចំនួន)
- គណៈកម្មាធិការត្រួតពិនិត្យ (មានប្រធាន អនុប្រធាន ១រូប សមាជិក ១ឬ៣រូប និងជំនួយការមួយចំនួន)
- គណៈកម្មាធិការហិរញ្ញវត្ថុ (មានប្រធាន អនុប្រធាន១រូប សមាជិក និងជំនួយការមួយចំនួន)
- គណៈចលនាមហាជន (មានអភិបាលរាជធានី ខេត្ត ជាប្រធាន អនុប្រធាន សមាជិក និងជំនួយការមួយចំនួន)
- យុវជនគណបក្សថ្នាក់រាជធានី ខេត្ត ។

## II. គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ

### ១. រចនាសម្ព័ន្ធចាត់តាំង

- រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ត្រូវមានមន្ត្រីវ័យចាស់ វ័យក្មេង នារីភេទ ជនជាតិភាគតិច (នៅមូលដ្ឋានដែលមានជនជាតិភាគតិចច្រើន) ជាមន្ត្រីគណបក្សដែលមានលក្ខណសម្បត្តិល្អប្រពៃ មានទស្សនៈ គោលជំហរនយោបាយរឹងមាំ ប្រកបដោយគុណធម៌ល្អ មានទំនាក់ទំនងល្អជាមួយមហាជន ប្រជាជន មានសមត្ថភាព និងលទ្ធភាពរ៉ាប់រងការងារគណបក្សដែលបានប្រគល់ជូន ។

- សមាសភាពគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ រួមមានអភិបាល អភិបាលរង ប្រធាន និងសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (មន្ត្រីដែលមានបទពិសោធន៍ក្នុងការដឹកនាំ និងមានឥទ្ធិពលល្អ) ប្រធានគណៈ ប្រធានស្នាក់ការគណបក្ស មន្ត្រីដឹកនាំកងកម្លាំងប្រដាប់អាវុធ មន្ត្រីដឹកនាំការិយាល័យ ផ្នែកមួយចំនួនជុំវិញក្រុង ស្រុក ខណ្ឌ ប្រធានគណៈកម្មាធិការគណបក្សឃុំ សង្កាត់ ប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋាន ។

គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស រួមមានប្រធានក្រុមប្រឹក្សា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ (មន្ត្រីដែលមានបទពិសោធន៍ក្នុងការដឹកនាំនិងមានឥទ្ធិពលល្អ) ប្រធានគណៈ ប្រធានស្នាក់ការគណបក្ស មន្ត្រីដឹកនាំក្នុងកងកម្លាំងប្រដាប់អាវុធ និងការិយាល័យ ផ្នែកសំខាន់ៗជុំវិញក្រុង ស្រុក ខណ្ឌ ។

+ ជាគោលការណ៍រួម អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបានពិនិត្យរៀបចំជាប្រធានគណៈកម្មាធិការគណបក្ស ។ ករណីជាក់ស្តែងមួយចំនួនប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាចជាប្រធានគណៈកម្មាធិការគណបក្ស និងទទួលបន្ទុកប្រចាំការស្នាក់ការគណបក្ស ។

### ២. បរិមាណ

បរិមាណសមាជិកគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់ :

- មានចំនួន ៣៣រូបចុះ ចំពោះក្រុង ស្រុក ខណ្ឌ ដែលមាន ១១ឃុំ សង្កាត់ ឡើងទៅ
- មានចំនួន ២៧រូបចុះ ចំពោះក្រុង ស្រុក ខណ្ឌ ដែលមាន ១០ឃុំ សង្កាត់ ចុះ ។

+ អាចពង្រីកបន្ថែមបរិមាណសមាជិកគណៈកម្មាធិការគណបក្ស នៅក្នុងជួរសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

+ គណៈអចិន្ត្រៃយ៍មានចំនួនមិនលើស ១ភាគ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្សទាំងមូល ។

+ អនុប្រធានគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ មានចំនួន២រូប ក្នុងនោះអនុប្រធាន ១រូប ជាអនុប្រធានប្រចាំការ និងជាប្រធានស្នាក់ការគណបក្ស ។ ក្រុង ស្រុក ខណ្ឌ ដែលមានគណបក្សមូលដ្ឋាន និងគណៈកម្មាធិការសាខាគណបក្សចំណុះផ្ទាល់ចំនួន ១២ឡើងទៅ អាចរៀបចំឱ្យមានអនុប្រធាន ៣រូប ។

### ៣. អង្គភាពជំនួយការគណបក្ស

អង្គភាពជំនួយការគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ រួមមាន :

- ស្នាក់ការគណបក្ស (មានប្រធាន អនុប្រធាន និងជំនួយការមួយចំនួន)
- គណៈចាត់តាំង (មានប្រធាន អនុប្រធាន ១រូប និងជំនួយការ២រូប)
- គណៈឃោសនាអប់រំ (មានប្រធាន អនុប្រធាន ១រូប និងជំនួយការមិនលើសពី ៣រូប)
- គណៈកម្មាធិការត្រួតពិនិត្យ (មានប្រធាន អនុប្រធាន ១រូប អនុប្រធានគណៈចាត់តាំង១រូប ជាសមាជិកទទួលបន្ថែម និងជំនួយការ ១ឬ២រូប)

- គណៈកម្មាធិការហិរញ្ញវត្ថុ (មានប្រធាន អនុប្រធាន ១រូប សមាជិកនិងជំនួយការមួយចំនួន)
- គណៈចលនាមហាជន (មានអភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធាន អនុប្រធាន និងសមាជិកមួយចំនួន)
- យុវជនគណបក្សថ្នាក់ក្រុង ស្រុក ខណ្ឌ ។

III. **គណៈកម្មាធិការគណបក្សឃុំ សង្កាត់**

១- រចនាសម្ព័ន្ធចាត់តាំង

- រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សឃុំ សង្កាត់ ត្រូវមានមន្ត្រីវ័យចាស់ វ័យក្មេង នារីភេទ ជនជាតិភាគតិច (នៅមូលដ្ឋានដែលមានជនជាតិភាគតិចច្រើន) ជាមន្ត្រីសំខាន់ៗនៅឃុំ សង្កាត់ ភូមិ ដែលមានលក្ខណសម្បត្តិល្អប្រពៃ មានទស្សនៈ គោលជំហរនយោបាយរឹងមាំ មានគុណធម៌ សីលធម៌ល្អ មានប្រជាប្រិយភាពក្នុងមហាជនប្រជាជន មានសមត្ថភាព និងមានស្មារតីសកម្មអនុវត្តភារកិច្ចការងារគណបក្សដែលបានប្រគល់ជូន ។

- សមាសភាពគណៈកម្មាធិការគណបក្សឃុំ សង្កាត់ រួមមានមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ ប្រធានប៉ុស្តិ៍រដ្ឋបាល ប្រធានសាខាគណបក្សភូមិ នាយកវិទ្យាល័យ អនុវិទ្យាល័យ ប្រធានមណ្ឌលសុខភាព ប្រធានអង្គភាពអាជីវកម្ម និងផលិតកម្មមួយចំនួន ។

+ ប្រធាន ឬអនុប្រធានគណៈកម្មាធិការគណបក្សឃុំ សង្កាត់(ដែលមិនមែនជាមេឃុំ ចៅសង្កាត់) ត្រូវទទួលបន្ទុកជាប្រធានស្នាក់ការគណបក្ស និងមានមន្ត្រីជំនួយការ ២រូប ដើម្បីប្រចាំការដោះស្រាយការងារគណបក្ស និងទំនាក់ទំនងជួបប្រាស្រ័យជាមួយសមាជិកគណបក្ស និងប្រជាជននៅមូលដ្ឋាន ។

២- បរិមាណ

បរិមាណសមាជិកគណៈកម្មាធិការគណបក្សឃុំ សង្កាត់ ត្រូវបានកំណត់ :

- មានចំនួន ២៧រូបចុះ ចំពោះឃុំ សង្កាត់ដែលមាន ៩-១១ អាសនៈក្រុមប្រឹក្សា
- មានចំនួន ២១រូបចុះ ចំពោះឃុំ សង្កាត់ដែលមាន ៥-៧ អាសនៈក្រុមប្រឹក្សា

គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សឃុំ សង្កាត់ មានចំនួនមិនលើស ១ភាគ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្សទាំងមូល ។ អនុប្រធានមានចំនួន ១រូប ឬ២រូប ។

IV- **គណៈកម្មាធិការគណបក្សមូលដ្ឋាន**

១- គោលការណ៍អំពីអង្គការមូលដ្ឋានរបស់គណបក្ស

- អង្គការមូលដ្ឋានរបស់គណបក្ស គឺជាអង្គការចាត់តាំងគណបក្ស ដែលត្រូវបង្កើតឡើងនៅមូលដ្ឋាន ជាគណៈកម្មាធិការគណបក្ស ឬសាខាគណបក្ស និងរួមទាំងអនុសាខា និងក្រុមបក្សចំណុះ ។

- នៅមូលដ្ឋានដែលមានសមាជិកគណបក្សពី ៣ នាក់ឡើងទៅ អាចបង្កើតសាខាគណបក្ស ។ សាខាគណបក្សដែលមានសមាជិកដល់ ៧ នាក់ ត្រូវជ្រើសតាំងប្រធាន ហើយអាចជ្រើសតាំងបន្ថែមអនុប្រធាន ។ សាខាគណបក្សដែលមានសមាជិកច្រើន ត្រូវជ្រើសតាំងគណៈកម្មាធិការសាខាគណបក្ស ។ គណៈកម្មាធិការសាខាគណបក្សជាអង្គការដឹកនាំរបស់សាខា ដែលត្រូវមានចំនួន ១១រូបចុះ និងមិនលើស ១ភាគ៣ នៃចំនួនសរុបសមាជិកគណបក្សក្នុងសាខា ។

នៅមូលដ្ឋានដែលមានសមាជិកគណបក្សចាប់ពី ៥០ នាក់ឡើងទៅ អាចបង្កើតគណៈកម្មាធិការគណបក្សមូលដ្ឋាន ។

- គណៈកម្មាធិការគណបក្សមូលដ្ឋានជាអង្គការចាត់តាំងមូលដ្ឋានរបស់គណបក្ស ដែលត្រូវបានបង្កើតឡើងនៅតាមឃុំ សង្កាត់ គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ អង្គភាពផលិតកម្ម អាជីវកម្ម សិប្បកម្ម រោងចក្រ សហគ្រាស អង្គការសង្គមនានា មន្ទីរអង្គភាពជុំវិញរាជធានី ខេត្ត អគ្គនាយកដ្ឋាននិងថ្នាក់ប្រហាក់ប្រហែលចំណុះក្រសួង ស្ថាប័ន ។

គណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវបានរៀបចំឱ្យមានសាខាគណបក្សចំណុះចំនួន ៣ ឡើងទៅ ។ ចំពោះសាខាគណបក្សចំណុះនៅមូលដ្ឋាន ឬផ្នែកណាដែលមានសមាជិកគណបក្សច្រើនត្រូវបង្កើតអនុសាខា និងចង់ក្រុងជាក្រុមបក្សចំណុះអនុសាខា ។

**២- រចនាសម្ព័ន្ធចាត់តាំង**

រចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវមានមន្ត្រីគណបក្ស ជាថ្នាក់ដឹកនាំសំខាន់ៗនៃអគ្គនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល មន្ទីរអង្គភាពជុំវិញរាជធានី ខេត្ត គ្រឹះស្ថាន អង្គភាពនៅមូលដ្ឋាន និងមន្ត្រីទទួលបន្ទុកការងារគណបក្ស (ប្រធានក្រុមការងាររបស់គណបក្ស ប្រធានសាខាគណបក្ស) ដែលរួមមានមន្ត្រីវ័យចាស់ វ័យក្មេង ស្ត្រី និងមានសមត្ថភាពដឹកនាំ មានសុខភាពល្អ មានលក្ខណសម្បត្តិល្អប្រពៃ មានទស្សនៈ គោលជំហរនយោបាយរឹងមាំ មានគុណធម៌ សីលធម៌ល្អ មានទំនាក់ទំនងល្អជាមួយមហាជន ប្រជាជន និងមានលទ្ធភាពរ៉ាប់រងការងារគណបក្សដែលបានប្រគល់ជូន ។

**៣- បរិមាណ**

បរិមាណសមាជិកគណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវបានកំណត់ :

- មានចំនួន២៧រូបចុះ ចំពោះគណៈកម្មាធិការគណបក្សដែលមានសាខាគណបក្សចំណុះចំនួន ១២ ឡើងទៅ
- មានចំនួន ២១ រូបចុះ ចំពោះគណៈកម្មាធិការគណបក្ស ដែលមានសាខាគណបក្សចំណុះចំនួន ១១ ចុះ ។

គណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សមូលដ្ឋានមានចំនួនមិនលើស ១ភាគ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្សមូលដ្ឋានទាំងមូល ។ អនុប្រធានមានចំនួន ១រូប ឬ២រូប ។

**៤- ការដឹកនាំ គ្រប់គ្រងគណៈកម្មាធិការគណបក្សមូលដ្ឋាន**

- គណៈកម្មាធិការគណបក្សមូលដ្ឋានមន្ទីរអង្គភាពជុំវិញរាជធានី ខេត្ត មន្ទីរពេទ្យបង្អែករាជធានី ខេត្ត គ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលនៅតាមខេត្ត ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។

- គណៈកម្មាធិការគណបក្សមូលដ្ឋានមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ វិទ្យាល័យ អនុវិទ្យាល័យ រោងចក្រ សហគ្រាស គ្រឹះស្ថាន អង្គភាពផលិតកម្ម អាជីវកម្ម សិប្បកម្ម និងអង្គការសង្គមនានា អាស្រ័យដោយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត រៀបចំស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ឬគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ស្របតាមសភាពការណ៍ជាក់ស្តែង ។

- គណៈកម្មាធិការគណបក្សនៃការិយាល័យចំណុះ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ។

## V- សិទ្ធិសម្រេចបង្កើតអង្គការចាត់តាំង និងរៀបចំមន្ត្រីគណបក្ស

**១- គណៈកម្មាធិការគណបក្សរាជធានី ខេត្ត មានសិទ្ធិសម្រេច :**

- បង្កើត ឬរំសាយ និងរៀបចំសមាសភាពគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះ សាខាគណបក្សចំណុះផ្ទាល់ គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស (ខ.២៦ ខ.២៧ ខ.១៨) ចំណុះ

- សម្រួលភារកិច្ច និងតែងតាំងសមាសភាពគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ចាប់ពីថ្នាក់អនុប្រធានចុះ

- សម្រួលភារកិច្ច និងតែងតាំងសមាសភាពគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការហិរញ្ញវត្ថុនៃគណបក្សក្រុង ស្រុក ខណ្ឌ

- សម្រួលភារកិច្ច និងតែងតាំងមន្ត្រីគណបក្សចំណុះផ្ទាល់ ចាប់ពីថ្នាក់អនុប្រធានគណៈ និងអនុប្រធានមន្ទីរគណបក្សចុះ

- សម្រួលភារកិច្ច និងតែងតាំងប្រធានគណៈ និងប្រធានផ្នែកចំណុះគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ

- សម្រួលភារកិច្ច និងតែងតាំងប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋាន ប្រធានគណៈកម្មាធិការគណបក្សឃុំ សង្កាត់ និងប្រធានស្នាក់ការគណបក្សឃុំ សង្កាត់

- សម្រួលភារកិច្ច និងតែងតាំង អនុប្រធាន និងសមាជិកយុវជនគណបក្សថ្នាក់រាជធានី ខេត្ត និងប្រធានយុវជនគណបក្សថ្នាក់ក្រុង ស្រុក ខណ្ឌ

- យល់ព្រមបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេស ចំពោះមន្ត្រីដែលមានឋានៈប្រធានការិយាល័យ អនុប្រធានមន្ទីរ អង្គភាព ជុំវិញរាជធានី ខេត្ត ឬថ្នាក់ប្រហាក់ប្រហែល

- លើកសំណើសុំសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល អំពីការបង្កើត និងតែងតាំងសមាសភាពគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការហិរញ្ញវត្ថុគណបក្សរាជធានី ខេត្ត

- លើកសំណើសុំសម្រួលភារកិច្ច និងតែងតាំង ចាត់តាំងមន្ត្រីគណបក្សដែលស្ថិតនៅក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់កណ្តាល

- លើកសំណើអំពីការរៀបចំបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតថ្នាក់ក្រោមជាតិ ដោយមានការឯកភាពជាមួយក្រុមការងារគណបក្សចុះមូលដ្ឋាន

- លើកសំណើអំពីមន្ត្រីគណបក្សដែលបានស្វាបស្ទង់ជាបេក្ខភាពសម្រាប់ស្នើតែងតាំងមុខតំណែងក្នុងរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរចនាសម្ព័ន្ធមន្ទីរអង្គភាពនានានៅថ្នាក់ក្រោមជាតិ

- ចូលរួមយោបល់អំពីការរៀបចំមន្ត្រីគណបក្សចូលកាន់មុខនាទីក្នុងមន្ទីរ អង្គភាពជុំវិញរាជធានី ខេត្ត ។

**២- គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ មានសិទ្ធិសម្រេច :**

- បង្កើត ឬរំសាយ និងរៀបចំសមាសភាពដឹកនាំសាខាគណបក្សចំណុះ និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស (ស.២៦ ស.២៧) ចំណុះ

- សម្រួលភារកិច្ច និងតែងតាំងសមាសភាពគណៈកម្មាធិការគណបក្សឃុំ សង្កាត់ និងគណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះ ចាប់ពីថ្នាក់អនុប្រធានចុះ

- សម្រួលភារកិច្ច និងតែងតាំងមន្ត្រីគណបក្សនៃបណ្តាគណៈ និងផ្នែកចំណុះផ្ទាល់ ចាប់ពីថ្នាក់អនុប្រធានគណៈ អនុប្រធានផ្នែក អនុប្រធានការិយាល័យចុះ

- សម្រួលភារកិច្ច និងតែងតាំងអនុប្រធាន និងសមាជិកយុវជនគណបក្សថ្នាក់ក្រុង ស្រុក ខណ្ឌ និងប្រធានយុវជនគណបក្សថ្នាក់មូលដ្ឋាន និងឃុំ សង្កាត់

- លើកសំណើសុំសម្រួលភារកិច្ច និងតែងតាំង ចាត់តាំងមន្ត្រីគណបក្ស ដែលស្ថិតនៅក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់រាជធានី ខេត្ត

- លើកសំណើអំពីមន្ត្រីគណបក្សដែលបានស្នាបស្នង់ជាបេក្ខភាពសម្រាប់ស្នើតែងតាំងមុខតំណែងនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការិយាល័យ ផ្នែកនានាជុំវិញក្រុង ស្រុក ខណ្ឌ

**៣- គណៈកម្មាធិការគណបក្សឃុំ សង្កាត់ និងគណៈកម្មាធិការគណបក្សមូលដ្ឋាន មានសិទ្ធិសម្រេច :**

- បង្កើត ឬរំសាយ និងរៀបចំអនុសាខា និងក្រុមបក្សចំណុះ
- សម្រួលភារកិច្ច និងតែងតាំងអនុប្រធាន និងសមាជិកយុវជនគណបក្សថ្នាក់មូលដ្ឋាន ឃុំ សង្កាត់ និងសមាសភាពក្រុមសកម្មជនយុវជនសាខាគណបក្សចំណុះ
- យល់ព្រមបញ្ចូលសមាជិកគណបក្ស
- លើកសំណើសុំសម្រួលភារកិច្ច និងតែងតាំង ចាត់តាំងមន្ត្រីគណបក្សដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់ក្រុង ស្រុក ខណ្ឌ

**៤- លក្ខណសម្បត្តិមន្ត្រីគណបក្ស**

ការពិនិត្យវាយតម្លៃមន្ត្រីគណបក្សត្រូវផ្អែកលើលក្ខណសម្បត្តិ៤យ៉ាងគឺ គោលជំហរ សុខភាព សមត្ថភាព និងប្រជាប្រិយភាព ។ មន្ត្រីគណបក្សត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម :

មួយ : មានគោលជំហរស្មោះត្រង់ដាច់ខាតចំពោះគណបក្ស និងផលប្រយោជន៍ជាតិ និងប្រជាជន គឺត្រូវមានស្មារតីតស៊ូការពារគណបក្ស ហ៊ានធ្វើពលិកម្មដើម្បីផលប្រយោជន៍ជាតិ និងប្រជាជន ។

ពីរ : មានសុខភាពអាចបំពេញភារកិច្ចបាន ។

បី : មានសមត្ថភាពទទួលរ៉ាប់រងសម្រេចបាននូវភារកិច្ចដែលបានប្រគល់ជូន គឺត្រូវមានការយល់ដឹងអំពីកម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយរបស់គណបក្ស និងមានសមត្ថភាពដឹកនាំចាត់តាំងអនុវត្តឱ្យសម្រេចបានជោគជ័យ ។

បួន : មានប្រជាប្រិយភាព ទទួលបានការគាំទ្រក្នុងគណបក្ស និងពីមហាជន ប្រជាជន គឺត្រូវមានភាពគំរូល្អក្នុងការងារ គោរពវិន័យអង្គការចាត់តាំង គោរពច្បាប់ ថែរក្សាសាមគ្គីភាពឯកភាពផ្ទៃក្នុង និងគំរូល្អក្នុងជីវភាពរស់នៅ ។

**៥- សំណុំបែបបទនៃការស្នើសុំរៀបចំមន្ត្រីគណបក្ស ត្រូវមាន :**

- សំណើរបស់គណៈកម្មាធិការគណបក្ស
- កំណត់ហេតុប្រជុំគណៈកម្មាធិការគណបក្ស ឬការផ្តល់មតិជាលាយលក្ខណអក្សរ
- បញ្ជីវត្តមានចូលរួមប្រជុំ
- បញ្ជីរាយនាមសមាសភាពមន្ត្រីដែលត្រូវបានស្នើសុំរៀបចំ
- ជីវប្រវត្តិសង្ខេបរបស់មន្ត្រីដែលត្រូវបានស្នើសុំតែងតាំង ចាត់តាំង មានបិទរូបថត និងមានបញ្ជាក់ពីថ្ងៃខែឆ្នាំចូលជាសមាជិកគណបក្ស
- មតិឯកភាពរបស់ប្រធានក្រុមការងារគណបក្សចុះមូលដ្ឋាន ។

## ផ្នែកទី ៣ : គោលការណ៍ការងារគ្រប់គ្រងកសាងពង្រឹងពង្រីកសមាជិកគណបក្ស

អង្គការមូលដ្ឋានរបស់គណបក្ស គឺជាអង្គការចាត់តាំងគណបក្ស ដែលត្រូវបង្កើតឡើងនៅមូលដ្ឋាន ជាគណៈកម្មាធិការគណបក្ស ឬជាសាខាគណបក្ស និងរួមទាំងអនុសាខា និងក្រុមបក្សចំណុះ ។

អង្គការមូលដ្ឋានរបស់គណបក្ស ជាថ្នាក់គណបក្សដែលមានសារសំខាន់បំផុតក្នុងការគ្រប់គ្រងកសាងពង្រឹងពង្រីកសមាជិកគណបក្ស និងដឹកនាំចាត់តាំងប្រមូលកម្លាំងចូលរួមអនុវត្តកម្មវិធីនយោបាយ គោលការណ៍ និងគោលនយោបាយរបស់គណបក្សឱ្យសម្រេចបានជោគជ័យ ។

I- **គណៈកម្មាធិការគណបក្សមូលដ្ឋានមានតួនាទី** (ប្រការ ២៦ នៃបទបញ្ជាផ្ទៃក្នុងគណបក្ស):

១- ក្ដាប់ជាប់នូវកម្មវិធីនយោបាយរបស់គណបក្ស ដើម្បីចាត់តាំងអនុវត្តឱ្យស្របតាមសភាពការណ៍ជាក់ស្ដែងនៅមូលដ្ឋាន ។

២- ដឹកនាំការងារគណបក្ស អំពីការងារនយោបាយ សតិអារម្មណ៍ និងចាត់តាំង ក្នុងក្របខណ្ឌមូលដ្ឋានរបស់ខ្លួន ។

៣- ផ្សារភ្ជាប់ជិតស្និទ្ធជាមួយមហាជន ប្រជាជននៅមូលដ្ឋាន ខិតខំបំផុសមហាជនចូលរួមកសាងពង្រឹងរដ្ឋអំណាច និងកែលម្អជីវភាពរស់នៅ ។

៤- ការពារឥទ្ធិពល និងប្រជាប្រិយភាពរបស់គណបក្ស ខិតខំប្រមូលកម្លាំងមហាជនច្រើនកុះករឱ្យគាំទ្រគណបក្សប្រជាជនកម្ពុជា ។

II- **សាខាគណបក្សមានភារកិច្ច** (មាត្រាទី ១៥ នៃលក្ខន្តិកៈគណបក្ស):

១- ក្ដាប់ជាប់នូវកម្មវិធីនយោបាយរបស់គណបក្ស និងច្បាប់របស់រដ្ឋ ដើម្បីចាត់តាំងអនុវត្តឱ្យបានសមស្របតាមសភាពការណ៍ជាក់ស្ដែងនៃមូលដ្ឋានរបស់ខ្លួន ។

២- សហការជាមួយអង្គការសង្គម ដើម្បីឃោសនាបំផុសចលនាប្រជាជនចូលរួមកសាងពង្រឹងរដ្ឋអំណាច យកចិត្តទុកដាក់ដោះស្រាយជីវភាពរស់នៅ ទាំងស្មារតី និងសម្ភារៈដល់ប្រជាជន ។

៣- បែងចែក និងត្រួតពិនិត្យការងាររបស់សមាជិកគណបក្សម្នាក់ៗ អប់រំសមាជិក (~~បញ្ចូលសមាជិកថ្មី លើកសរសើរ ដាក់វិន័យសមាជិក កសាងជួរមន្ត្រី~~) និងថែរក្សាសាមគ្គីភាព ។

៤- ធ្វើរបាយការណ៍អំពីសភាពការណ៍ និងសុំយោបល់សម្រេចពីថ្នាក់លើនូវបញ្ហាសំខាន់ៗ ។

បញ្ជាក់ : ក្នុងការអនុវត្តជាក់ស្ដែងបច្ចុប្បន្ននេះ ការបញ្ចូលសមាជិកថ្មី ការលើកសរសើរ និងដាក់វិន័យសមាជិក និងការកសាងជួរមន្ត្រី ជាភារកិច្ចរបស់គណៈកម្មាធិការគណបក្សថ្នាក់លើរបស់សាខាគណបក្ស ។ មាត្រាទី ៦ នៃលក្ខន្តិកៈគណបក្សចែងថា គណៈកម្មាធិការគណបក្សមូលដ្ឋានពិនិត្យសម្រេចបញ្ចូលសមាជិក... ។

III- **សមាជិកគណបក្សមានភារកិច្ច** (មាត្រាទី ៧ នៃលក្ខន្តិកៈគណបក្ស):

១- ខិតខំប្រតិបត្តិឱ្យបានត្រឹមត្រូវតាមកម្មវិធីនយោបាយ និងលក្ខន្តិកៈរបស់គណបក្ស ។

២- កសាងទំនាក់ទំនងល្អជាមួយប្រជាជន និងខិតខំឃោសនាផ្សព្វផ្សាយ អំពីកម្មវិធីនយោបាយរបស់គណបក្ស ច្បាប់របស់រដ្ឋដល់ប្រជាជន ។

៣- ត្រូវថែរក្សាផ្ដួងសាមគ្គីឯកភាពផ្ទៃក្នុង រក្សាការសម្ងាត់របស់គណបក្ស ជានិច្ចកាលជួយមតិគ្នាទៅវិញទៅមកដើម្បីការរីកចម្រើន ។

៤- ខិតខំរៀនសូត្រលើកកម្ពស់សមត្ថភាព និងគុណធម៌ ដើម្បីសម្រេចភារកិច្ចជូនជាតិមាតុភូមិ ។

IV- **ប្រធានក្រុមបក្សមានភារកិច្ច** :

១- ត្រូវគ្រប់គ្រងចំនួនសមាជិកក្នុងក្រុមឱ្យបានល្អ ប្រធានក្រុម និងសមាជិកត្រូវស្គាល់គ្នាទៅវិញទៅមក ។

២- ត្រូវអប់រំសមាជិកក្នុងក្រុមឱ្យស្រឡាញ់ និងគាំទ្រគណបក្សប្រជាជនកម្ពុជា ។

៣- ត្រូវដឹកនាំសមាជិកក្នុងក្រុមឱ្យពិនិត្យមើលឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

៤- ត្រូវធានាថា សមាជិកទាំងអស់ក្នុងក្រុមបានទៅបោះឆ្នោត ចេះបោះឆ្នោត និងបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជាដោយពិតប្រាកដ ។

* សមាជិកក្រុមបក្សទាំងអស់មានភារកិច្ចត្រូវពិនិត្យមើលឈ្មោះក្នុងបញ្ជីបោះឆ្នោត ទៅបោះឆ្នោតជូនគណបក្ស និងចេះចលនាសាច់ញាតិ និងអ្នកជិតខាងឱ្យបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា ។

V- **មេគ្រួសារបក្សមានភារកិច្ច** :

១- ត្រូវរួមជាមួយប្រធានក្រុមបក្ស ដើម្បីគ្រប់គ្រងសមាជិកក្នុងគ្រួសារបក្សឱ្យបានល្អ មានទំនាក់ទំនងល្អជាមួយគ្នា ស្រឡាញ់គ្នា សាមគ្គីគ្នា ជួយគ្នាទៅវិញទៅមក និងយកចិត្តទុកដាក់ពង្រីកសមាជិកបន្ថែម ។

២- ត្រូវអប់រំសមាជិកក្នុងគ្រួសារបក្សឱ្យស្រឡាញ់ និងគាំទ្រគណបក្សប្រជាជនកម្ពុជា ។

៣- ត្រូវដឹកនាំសមាជិកក្នុងគ្រួសារបក្សឱ្យពិនិត្យមើលឈ្មោះក្នុងបញ្ជីបោះឆ្នោត និងទៅបោះឆ្នោតឱ្យបានគ្រប់គ្នា ។

៤- ត្រូវធានាថា សមាជិកទាំងអស់ក្នុងគ្រួសារបក្សបានទៅបោះឆ្នោត ចេះបោះឆ្នោត និងបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជាដោយពិតប្រាកដ ។

៥- ត្រូវរាយការណ៍ជូនប្រធានក្រុមបក្ស អនុសាខាបក្ស សាខាគណបក្សភូមិ អំពីវត្តមាន ការប្រែប្រួលសតិអារម្មណ៍នយោបាយ និងការថ្នាំងថ្នាក់របស់សមាជិកក្នុងគ្រួសារបក្ស ដើម្បីមានវិធានការដោះស្រាយជាក់ស្តែងទាន់ពេលវេលា ។

VI- **ការរៀបចំអនុសាខា ក្រុមបក្ស និងការប្រជុំជីវភាពបក្ស**

អនុសាខា ដឹកនាំដោយប្រធាន និងអនុប្រធានមួយចំនួន ។ អនុសាខាដែលមានសមាជិកគណបក្សច្រើន ត្រូវរៀបចំចងក្រងជាក្រុមបក្សចំណុះអនុសាខា ។ ប្រធាន អនុប្រធានអនុសាខានៅមូលដ្ឋាន ត្រូវបានជ្រើសតាំងពីក្នុងចំណោមប្រធានក្រុមបក្ស ហើយត្រូវបានបែងចែកភារកិច្ចឱ្យទទួលបន្ទុកគ្រប់គ្រងផ្ទាល់ជាប្រធានក្រុមបក្សមួយ និងគ្រប់គ្រងលើក្រុមបក្សមួយចំនួនទៀតក្នុងអនុសាខា ។

ការរៀបចំចងក្រងជាក្រុមបក្ស សំដៅធានាការគ្រប់គ្រងសមាជិកគណបក្ស បម្រើសំណូមពរនៃការបោះឆ្នោត ។ ប្រធាន អនុប្រធាន និងសមាជិកក្នុងក្រុមបក្សត្រូវស្គាល់គ្នា និងមានទំនាក់ទំនងល្អជាមួយគ្នា ដើម្បីនាំគ្នាពិនិត្យមើលឈ្មោះក្នុងបញ្ជីបោះឆ្នោត និងទៅបោះឆ្នោតជូនគណបក្ស។ សមាជិកគណបក្សនៅក្នុងគ្រួសារតែមួយ ផ្ទះតែមួយ ត្រូវនៅក្នុងក្រុមបក្សជាមួយគ្នា ។ ក្រុមបក្សនីមួយៗ អាចមានមួយគ្រួសារបក្ស ឬច្រើនគ្រួសារបក្ស ។

ត្រូវរៀបចំការប្រជុំជីវភាពសមាជិកគណបក្សប្រចាំខែ ដើម្បីផ្សព្វផ្សាយអប់រំណែនាំសមាជិកគណបក្សឱ្យបានយល់ជ្រួតជ្រាបអំពីគោលនយោបាយ គោលការណ៍ ទិសដៅ ភារកិច្ចការងារគណបក្ស ក៏ដូចជាទស្សនៈគោលជំហររបស់គណបក្សចំពោះបញ្ហានានារបស់ប្រទេសជាតិ និងអន្តរជាតិ ព្រមទាំងដោះស្រាយបញ្ហាជាក់ស្តែងនានា តាមរយៈការប្រជុំគណៈកម្មាធិការសាខាគណបក្សបើកទូលាយ ដោយមានការចូលរួមរបស់ប្រធាន អនុប្រធានអនុសាខា និងប្រធានក្រុមបក្ស ។ ប្រធានក្រុមបក្សត្រូវបន្តផ្សព្វផ្សាយដល់សមាជិកក្នុងក្រុមបក្សរបស់ខ្លួន ។

VII. **គោលការណ៍មួយចំនួននៃការងារគ្រប់គ្រងសមាជិកគណបក្ស**

១- សមាជិកគណបក្សម្នាក់ៗ ដែលបានចូលជាសមាជិកគណបក្សប្រជាជនកម្ពុជាត្រូវបានទទួលសេចក្តីសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស និងត្រូវបានផ្តល់ប័ណ្ណសម្គាល់សមាជិកគណបក្ស ។

២- គណៈកម្មាធិការគណបក្សមូលដ្ឋាន និងសាខាគណបក្ស ត្រូវមានបញ្ជីរាយនាមសមាជិកគណបក្ស និងបញ្ជីស្ថិតិសមាជិកគណបក្ស សម្រាប់ការគ្រប់គ្រងសមាជិកគណបក្សនៅថ្នាក់របស់ខ្លួន និងរាយការណ៍ជូនអង្គការចាត់តាំងគណបក្សថ្នាក់លើ ។

៣- គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល ត្រូវមានបញ្ជីស្ថិតិសមាជិក និងអង្គការចាត់តាំងគណបក្សចំណុះរបស់ខ្លួន និងត្រូវចងក្រងបញ្ជីរាយនាមសមាជិកគណបក្ស សម្រាប់ការគ្រប់គ្រងសមាជិកគណបក្សផង និងការតាមដានបង្កលក្ខណៈជួយសម្រួលដល់សមាជិកគណបក្សក្នុងការពិនិត្យមើលឈ្មោះក្នុងបញ្ជីបោះឆ្នោត និងទៅបោះឆ្នោតផង ។

៤- ការងារតែងតាំងមន្ត្រីគណបក្ស និងការចាត់តាំងប្រគល់ភារកិច្ចការងារគណបក្ស ត្រូវបានអនុវត្តតែចំពោះមន្ត្រីដែលជាសមាជិកគណបក្សប្រជាជនកម្ពុជា ដោយមានឯកសារបញ្ជាក់ថ្ងៃខែឆ្នាំចូលជាសមាជិកគណបក្ស ។

**ឯកសារបញ្ជាក់អំពីសមាជិកគណបក្សរួមមាន :**

- ប័ណ្ណសម្គាល់សមាជិកគណបក្ស
- សេចក្តីសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស
- សេចក្តីសម្រេចយល់ព្រមទទួលស្គាល់ជាបក្ខជនពេញសិទ្ធិ
- លិខិតឧទ្ទេសនាមជីវភាពគណបក្ស
- សេចក្តីសម្រេចតែងតាំង ឬចាត់តាំងប្រគល់ភារកិច្ចការងារគណបក្ស
- ប័ណ្ណ ឬលិខិតសម្គាល់ខ្លួនមន្ត្រីបុគ្គលិកស្ថាប័នគណបក្ស
- លិខិតបញ្ជាក់របស់គណៈកម្មាធិការគណបក្សដែលសាមីខ្លួនធ្លាប់បានចូលរួមជីវភាពគណបក្ស ដោយមានសមាជិកគណបក្ស ២រូប នៅក្នុងអង្គការចាត់តាំងគណបក្សនៅទីនោះជាអ្នកជានាដឹងឮ ។

៥- អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ ត្រូវអនុវត្តរបបប្រជុំជីវភាពគណបក្សប្រចាំខែទៀងទាត់ ស្របតាមគោលការណ៍កំណត់ ។ សមាជិកគណបក្ស មិនអាចខកខានមិនចូលរួមប្រជុំជីវភាពសាខាគណបក្សរយៈពេល ៣ខែ ដោយគ្មានមូលហេតុត្រឹមត្រូវបានឡើយ ។

៦- គណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវធ្វើលិខិតឧទ្ទេសនាមផ្ទេរជីវភាពជូនសមាជិកគណបក្សដែលត្រូវផ្ទេរចេញទៅស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការចាត់តាំងគណបក្សមួយទៀត ។ ការផ្ទេរជីវភាពសមាជិកគណបក្ស ដែលមានតួនាទីជាមន្ត្រីគណបក្ស ត្រូវចម្លងជូនភ្ជាប់ជាមួយនូវជីវប្រវត្តិ ដោយមានចុះហត្ថលេខា និងបោះត្រាបញ្ជាក់របស់គណៈកម្មាធិការគណបក្ស ឬគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល ។

VIII. **បែបបទនៃការបញ្ចូលសមាជិកគណបក្ស**

១- សាមីខ្លួនធ្វើពាក្យសុំចូលជាសមាជិកគណបក្ស ដោយភ្ជាប់ជាមួយជីវប្រវត្តិ ។

២- មានសមាជិកគណបក្ស ២នាក់ជាអ្នកឧទ្ទេសនាម ។ អ្នកឧទ្ទេសនាមគឺជាសមាជិកគណបក្សដែលរួមការងារជាមួយ ឬបានរស់នៅមូលដ្ឋានជាមួយអ្នកសុំចូលជាសមាជិកគណបក្ស ហើយជាអ្នកជានាដឹងឮអំពីជីវប្រវត្តិ សកម្មភាព និងលក្ខណសម្បត្តិរបស់អ្នកសុំចូលជាសមាជិកគណបក្ស ។

៣- គណៈកម្មាធិការសាខាគណបក្ស ពិនិត្យសំណុំបែបបទសុំចូលជាសមាជិកគណបក្សម្នាក់ៗ ហើយធ្វើបញ្ជីរួមរាយការណ៍ជូនគណៈកម្មាធិការគណបក្សថ្នាក់លើពិនិត្យ ។

៤- គណៈកម្មាធិការគណបក្សដែលដឹកនាំគ្រប់គ្រងផ្ទាល់សាខាគណបក្ស ពិនិត្យ និងចេញសេចក្ដីសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស ហើយស្នើសុំគណៈកម្មាធិការគណបក្ស ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្ដល់ប័ណ្ណសម្គាល់សមាជិកគណបក្ស ។

៥- ចាត់តាំងពិធីបញ្ចូលសមាជិកគណបក្សថ្មីនៅសាខាគណបក្ស ឬពិធីប្រកាសបញ្ចូលសមាជិកគណបក្សរួមមកពីច្រើនសាខាគណបក្ស ។

៦- ចំពោះការបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេស ត្រូវអនុវត្តតាមបែបបទ :

- អនុវត្តតាមស្មារតីនៃសេចក្ដីណែនាំលេខ ៣៧ សណ.គក ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ ស្ដីពីការគ្រប់គ្រងសមាជិកគណបក្សក្នុងករណីពិសេស ចំពោះការសុំចូលជាសមាជិកគណបក្សប្រជាជនកម្ពុជារបស់ឥស្សរជនដែលមានឥទ្ធិពលក្នុងសង្គម មន្ត្រីជាន់ខ្ពស់នៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ព្រឹទ្ធសភា ចាប់ពីថ្នាក់សមាជិកគណៈកម្មាធិការនាយកឡើងទៅ នាយទាហានជាន់ខ្ពស់ នាយនគរបាលជាន់ខ្ពស់ និងមន្ត្រីដែលជាសមាជិកគណបក្សនយោបាយនានា ចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែលនៅក្រសួង ស្ថាប័ន និងចាប់ពីថ្នាក់ប្រធានមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែលនៅរាជធានី ខេត្ត ត្រូវបានពិនិត្យសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស ដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល

- គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាលប្រគល់សិទ្ធិជូនគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ពិនិត្យសម្រេចបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេសចំពោះអ្នកដែលមានឋានៈនាទីត្រឹមប្រធានការិយាល័យចុះ ឬថ្នាក់ប្រហាក់ប្រហែល នៅក្រសួង ស្ថាប័ន និងថ្នាក់អនុប្រធានមន្ទីរចុះ ឬថ្នាក់ប្រហាក់ប្រហែលនៅរាជធានី ខេត្ត

- សាមីខ្លួនត្រូវបំពេញបែបបទធ្វើពាក្យសុំចូលជាសមាជិកគណបក្សប្រជាជនកម្ពុជាដោយភ្ជាប់ជាមួយជីវប្រវត្តិ ពាក្យសុំលាលែងពីគណបក្សនយោបាយចាស់ និងមានសមាជិកគណបក្ស ២ នាក់ជាអ្នកឧទ្ទេសនាម និងជានាដឹងឮអំពីជីវប្រវត្តិ សកម្មភាព និងលក្ខណសម្បត្តិរបស់ខ្លួន

- គណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាល គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត មានភារកិច្ចរៀបចំពិធីបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេស

- សមាជិកគណបក្សក្នុងករណីពិសេស ត្រូវបានរៀបចំឱ្យចូលរួមជីវភាពបក្សនៅក្នុងសាខាពិសេស ឬក្រុមសមាជិកដែលស្ថិតក្រោមការគ្រប់គ្រងដឹកនាំផ្ទាល់របស់ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬនៅតាមសាខាគណបក្សនានាស្របតាមសំណូមពរការងារ និងសភាពការណ៍ជាក់ស្ដែង ។

សមាជិកគណបក្សក្នុងករណីពិសេសមិនអាចចូលរួមក្នុងសកម្មភាពរបស់គណបក្សដទៃឡើយ បើសិនជាគ្មានការចាត់តាំងប្រគល់ភារកិច្ចពីគណបក្ស ។

## ផ្នែកទី ៤ : គោលការណ៍ការងារគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស និងមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា

### I. គោលការណ៍ណែនាំរបស់គណបក្ស

១- សេចក្ដីណែនាំលេខ ២០/១៧ សណ.គក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៧ ស្ដីពីវិធានការមួយចំនួនសម្រាប់អនុវត្តយុទ្ធសាស្ត្រ "**សមាជិកបក្សមួយរូប គឺជាសំឡេងឆ្នោតគាំទ្រគណបក្សមួយសន្លឹក**" បានដាក់ចេញនូវវិធានការធ្វើបច្ចុប្បន្នភាពចំនួនសមាជិកគណបក្ស និងផ្ដល់ប័ណ្ណសមាជិកគណបក្ស ដោយបានកំណត់យកគ្រួសារបក្សជាមូលដ្ឋាន និងធ្វើសៀវភៅគ្រួសារបក្ស ។

២- សេចក្ដីណែនាំលេខ ០០៩/១១២០ សណ.គក ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០២០ ស្ដីពី "**ការធ្វើបញ្ជីសមាជិកគណបក្សប្រជាជនកម្ពុជាតាមគំរូឯកភាព**" ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងបញ្ជីសមាជិកគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា ។

៣- ចំណារឯកភាពជាគោលការណ៍របស់**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** អនុប្រធានគណបក្ស និងជាប្រធានគណៈប្រចាំការ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០២១ ស្ដីពី "**ការធ្វើបញ្ជីសមាជិកគណបក្សតែមួយគ្រប់គ្រងដោយគណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាល**" ។

៤- ចំណារឯកភាពជាគោលការណ៍របស់**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** អនុប្រធានគណបក្ស និងជាប្រធានគណៈប្រចាំការ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០២៣ អំពី "**ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា និងការរៀបចំ QR Code**" ។

៥- សេចក្ដីណែនាំលេខ: ០០១/០១២៥/សណ.គក ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០២៥ ស្ដីពី "**ការងារគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស និងមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា**" ។

### II. ការរៀបចំ និងបណ្ដុះបណ្ដាលមន្ត្រីជំនាញ IT

គណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាលបានផ្ដល់គណនី Data Entry ជូនមន្ត្រីជំនាញ IT គណបក្សនៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងបើកវគ្គបណ្ដុះបណ្ដាលបំពាក់បំប៉ន សម្រាប់ចូលរួមធ្វើការបញ្ចូល និងកែទិន្នន័យក្នុងប្រព័ន្ធ Server ។ ការផ្ដល់គណនីសម្រាប់មន្ត្រីគណបក្សចូលធ្វើការក្នុងប្រព័ន្ធ រួមមាន:

- គណនី Read Only ចំនួន ២ និងគណនី Data Entry ចំនួន ២ សម្រាប់ក្រសួង ស្ថាប័ននីមួយៗ
- គណនី Read Only ចំនួន ១ និងគណនី Data Entry ចំនួន ១ សម្រាប់គណបក្សមូលដ្ឋាននីមួយៗចំណុះក្រសួង ស្ថាប័ន
- គណនី Read Only ចំនួន ៣ និងគណនី Data Entry ចំនួន ៣ សម្រាប់រាជធានី ខេត្តនីមួយៗ
- គណនី Read Only ចំនួន ២ និងគណនី Data Entry ចំនួន ២ សម្រាប់ក្រុង ស្រុក ខណ្ឌនីមួយៗ
- គណនី Read Only ចំនួន ១ និងគណនី Data Entry ចំនួន ១ សម្រាប់ឃុំ សង្កាត់នីមួយៗ

ផ្ដល់សិទ្ធិជូនអ្នកប្រើប្រាស់គណនី Read Only ចំនួន ១ និងគណនី Data Entry ចំនួន ១ (ក្នុងចំណោមអ្នកប្រើប្រាស់គណនីដូចខាងលើនេះ) សម្រាប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ ចូលធ្វើការក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្ស ។

ផ្ដល់សិទ្ធិជូនអ្នកប្រើប្រាស់គណនី Read Only ចំនួន ១ និងគណនី Data Entry ចំនួន ១ សម្រាប់រាជធានី ខេត្តនីមួយៗ ចូលធ្វើការគ្រប់គ្រងបញ្ជីសមាជិកគណបក្សករណីពិសេសដោយឡែករបស់រាជធានី ខេត្ត ។

ក្រុម IT គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលរៀបចំកម្មវិធីជាតារាង Excel បញ្ជីរាយនាមសមាជិកគណបក្ស និងតារាង Excel បញ្ជីរាយនាមមន្ត្រីគណបក្ស និងបំពាក់បំប៉នដល់មន្ត្រី IT គណបក្សគ្រប់ថ្នាក់ ដើម្បីធ្វើការបញ្ចូល និងបញ្ជូនទិន្នន័យតាមតារាង Excel ជំនួសឱ្យការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ Sever ។

III. **ដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស**

១- ប្រព័ន្ធ Server គ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្សបើកដំណើរការចាប់ពីថ្ងៃទី ១ ខែមេសា ឆ្នាំ ២០២២ ។

២- បញ្ជីសមាជិកគណបក្សទាំងអស់នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត រហូតដល់មូលដ្ឋាន ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ Server ហើយបានប្រើប្រាស់ជាទិន្នន័យផ្លូវការសម្រាប់របាយការណ៍ស្ថិតិសមាជិកគណបក្ស ចាប់ពីខែមករា ឆ្នាំ ២០២៣ ។ សមាជិកគណបក្សត្រូវមានលក្ខណសម្បត្តិស្របតាមមាត្រាទី ៥ នៃលក្ខន្តិកៈគណបក្ស និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ **បញ្ជីសមាជិកគណបក្សនៅក្នុងប្រព័ន្ធ Server ត្រូវបានផ្ទៀងផ្ទាត់ជាមួយបញ្ជីបោះឆ្នោតដើម្បីធានាថាសមាជិកគណបក្សមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មានទិន្នន័យត្រឹមត្រូវដូចក្នុងអត្តសញ្ញាណប័ណ្ណ និងក្នុងបញ្ជីបោះឆ្នោត គ្មានឈ្មោះស្ទួន** ហើយអាចពិនិត្យមើល និងបោះពុម្ពចេញជាស្ថិតិសមាជិកគណបក្ស និងបញ្ជីសមាជិកគណបក្សតាមអង្គការចាត់តាំងគណបក្សនីមួយៗរហូតដល់សាខាគណបក្ស ក្រុមបក្ស សៀវភៅគ្រួសារបក្ស និងតាមការិយាល័យបោះឆ្នោត ។

បញ្ជីសមាជិកគណបក្សទាំងអស់នៅក្រៅប្រទេស ក៏ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ Server ដោយមិនតម្រូវឱ្យមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទេ ។

៣- ការបញ្ចូល និងកែទិន្នន័យនៅក្នុងប្រព័ន្ធ Server ត្រូវមានភ្ជាប់ជាមួយនូវសេចក្តីសម្រេច ឬឯកសារបញ្ជាក់ដោយគណៈកម្មាធិការគណបក្ស ស្របតាមគោលការណ៍ណែនាំអំពីការងារគ្រប់គ្រងសមាជិកគណបក្ស ក៏ដូចជាការងារគ្រប់គ្រងមន្ត្រីគណបក្ស ។

៤- ប័ណ្ណសមាជិកគណបក្សត្រូវបោះពុម្ពតាមទិន្នន័យចេញពីប្រព័ន្ធ Server ផ្តល់ជូនតាមសំណើរបស់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមការងារគណបក្សចុះមូលដ្ឋាន ។

ប័ណ្ណសមាជិកគណបក្ស ប័ណ្ណមន្ត្រីគណបក្ស និងសៀវភៅគ្រួសារបក្ស ដែលបានបោះពុម្ពតាមទិន្នន័យចេញពីប្រព័ន្ធ Server ត្រូវបានរៀបចំឱ្យមាន QR Code និងបើកឱ្យ Scan QR Code ដើម្បីផ្ទៀងផ្ទាត់ជាមួយទិន្នន័យក្នុងប្រព័ន្ធ Server ។

៥- ក្នុងប្រព័ន្ធ Server មានរៀបចំ Menu សម្រាប់បម្រើការងារគ្រប់គ្រងសមាជិកគណបក្សករណីពិសេសដោយឡែកមួយចំនួននៃរាជធានី ខេត្ត នីមួយៗ ។

៦- ក្នុងប្រព័ន្ធ Server មានរៀបចំបន្ថែមមុខងារសម្រាប់បញ្ចូលទិន្នន័យមុខសញ្ញាកសាងបក្សក្រោមអាយុ ១៨ឆ្នាំ ដែលមានអត្តសញ្ញាណប័ណ្ណ សំដៅបង្កលក្ខណសម្បត្តិដល់គណៈកម្មាធិការគណបក្ស និងអង្គការយុវជនរបស់គណបក្ស ក្នុងការគ្រប់គ្រង តាមដាន ជំរុញការកសាងពង្រីកសមាជិកគណបក្សជាយុវជន នៅពេលគ្រប់អាយុបោះឆ្នោត ។

IV. **<u>ដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្ស</u>**

១- ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្ស បើកដំណើរការចាប់ពីថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០២៤ ។

២- ទិន្នន័យមន្ត្រីគណបក្ស ត្រូវបានជ្រើសរើសចេញពីទិន្នន័យបញ្ជីសមាជិកគណបក្ស យកមកបន្ថែមទិន្នន័យមួយចំនួនទៀតបម្រើឱ្យការងារគ្រប់គ្រងមន្ត្រីគណបក្ស និងមានកម្មវិធីដើម្បីផ្ទៀងផ្ទាត់ទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រី និងប្រព័ន្ធគ្រប់គ្រងទិន្នន័យសមាជិកគណបក្សឱ្យបានត្រឹមត្រូវដូចគ្នា ចៀសវាងការបញ្ចូលទិន្នន័យ ២ដង ។ ត្រូវបញ្ចូលទិន្នន័យមន្ត្រីគណបក្សទាំងអស់ទៅក្នុងប្រព័ន្ធ Server ដើម្បីគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា និងប្រើប្រាស់សម្រាប់ការពិនិត្យវាយតម្លៃរៀបចំមន្ត្រី និងការរៀបចំបញ្ជីបេក្ខជនរបស់គណបក្ស ។

៣- ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្ស ត្រូវបានរៀបចំបន្ថែមកម្មវិធីសម្រាប់គ្រប់គ្រងទិន្នន័យការងារត្រួតពិនិត្យគណបក្ស ដែលបានបើកដំណើរការចាប់ពីថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០២៤ និងកម្មវិធីសម្រាប់គ្រង់គ្រងទិន្នន័យការងារចាត់តាំង និងការងារជំនាញផ្សេងៗរបស់គណបក្ស ។

គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលផ្តល់គណនី Read Only និងគណនី Data Entry សម្រាប់គណៈកម្មាធិការត្រួតពិនិត្យនៃគណៈកម្មាធិការកណ្តាលសម្រាប់ចូលធ្វើការក្នុងប្រព័ន្ធ Server ។ ស្នើគណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ចាត់តាំងប្រើប្រាស់ក្រុម IT គណបក្សថ្នាក់ខ្លួន ផ្តល់កិច្ចសហការចូលរួមបំពេញការងារនេះតាមសំណើរបស់ប្រធានគណៈកម្មាធិការត្រួតពិនិត្យគណបក្សគ្រប់ថ្នាក់ ៕

# គោលបំណង និងសំណូមពរ

១- លើកកម្ពស់ការយល់ដឹងអំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់គណៈចាត់តាំងនៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អំពីគោលការណ៍ការងាររៀបចំរចនាសម្ព័ន្ធ អង្គការចាត់តាំង និងមន្ត្រីគណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងអង្គការចាត់តាំងគណបក្សចំណុះ អំពីគោលការណ៍ការងារគ្រប់គ្រងសមាជិកគណបក្ស និងមន្ត្រីគណបក្ស ។

២- លើមូលដ្ឋាននេះ ពង្រឹងលើកកម្ពស់សមត្ថភាព និងស្មារតីទទួលខុសត្រូវរបស់គណៈចាត់តាំង និងមន្ត្រីទទួលបន្ទុកការងារចាត់តាំងគ្រប់ថ្នាក់ ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមគោលការណ៍កំណត់របស់គណបក្ស ធ្វើជាសេនាធិការជូនគណៈកម្មាធិការគណបក្ស ដើម្បីពង្រឹងប្រសិទ្ធភាពនៃការដឹកនាំរបស់អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ ពង្រឹងសាមគ្គីភាពឯកភាពផ្ទៃក្នុង និងជំនឿគាំទ្រចំពោះគណបក្ស ។

## ឯកសារ
## បំពាក់បំប៉នការងារចាត់តាំងគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ផ្នែកទី ១**: គោលការណ៍ការងារចាត់តាំងកសាងគណបក្ស និងតួនាទី ភារកិច្ចរបស់គណៈចាត់តាំង

I- គោលការណ៍ការងារចាត់តាំងកសាងគណបក្ស

II- តួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំងរបស់គណៈចាត់តាំង

**ផ្នែកទី ២**: គោលការណ៍ការងាររៀបចំរចនាសម្ព័ន្ធ អង្គការចាត់តាំង និងមន្ត្រីគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គការចាត់តាំងមូលដ្ឋានចំណុះ

I- គណៈកម្មាធិការគណបក្សរាជធានី ខេត្ត

II. គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ

III. គណៈកម្មាធិការគណបក្សឃុំ សង្កាត់

IV- គណៈកម្មាធិការគណបក្សមូលដ្ឋាន

V- សិទ្ធិសម្រេចបង្កើតអង្គការចាត់តាំង និងរៀបចំមន្ត្រីគណបក្ស

**ផ្នែកទី ៣**: គោលការណ៍ការងារគ្រប់គ្រងកសាងពង្រឹងពង្រីកសមាជិកគណបក្ស

I- តួនាទី គណៈកម្មាធិការគណបក្សមូលដ្ឋាន

II- ភារកិច្ចសាខាគណបក្ស

III- ភារកិច្ចសមាជិកគណបក្ស

IV- ភារកិច្ចប្រធានក្រុមបក្ស

V- ភារកិច្ចមេគ្រួសារបក្ស

VI- ការរៀបចំអនុសាខា ក្រុមបក្ស និងការប្រជុំជីវភាពបក្ស

VII. គោលការណ៍មួយចំនួននៃការងារគ្រប់គ្រងសមាជិកគណបក្ស

VIII. បែបបទនៃការបញ្ចូលសមាជិកគណបក្ស

**ផ្នែកទី ៤** : គោលការណ៍ការងារគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស និងមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា

I. គោលការណ៍ណែនាំរបស់គណបក្ស

II. ការរៀបចំ និងបណ្តុះបណ្តាលមន្ត្រីជំនាញ IT

III. ដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស

IV. ដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្ស